ឆ្នាំទី៤ លេខ៤១ ចេញផ្សាយប្រចាំខែមករា ឆ្នាំ២០១៤

# ព្រឹត្តិបត្រការងារ
# Labour Bulletin

ជាស្ពានរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាន់ ♦ ការងារ ♦ កម្លាំងពលកម្ម ♦ ព័ត៌មានទីផ្សារការងារ ✧ Government gateway to ♦ Job ♦ Workforce ♦ Labour Market Information



រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល


♦ សកម្មភាពថ្មីៗពាក់ព័ន្ធវិស័យការងារ [ទំព័រ១]

♦ ព័ត៌មានទីផ្សារការងារនៅកម្ពុជា [ទំព័រ ៥]

♦ ព័ត៌មានជ្រើសរើសបុគ្គលិក [ទំព័រ ៨]

♦ កំសាន្ត និងប្រាជ្ញា [ទំព័រ ១៦]

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ព្រឹត្តិបត្រការងារ

# មាតិកា

## y ព័ត៌មាន និងសកម្មភាព

❑ សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្តុះបណ្តាល ........ [ទំព័រ ១]

## y ព័ត៌មានទីផ្សារការងារនៅកម្ពុជា

❑ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ពីខែមីនា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១៤ [ទំព័រ ៥]

## y ព័ត៌មានជ្រើសរើសបុគ្គលិក

❑ ព័ត៌មានជ្រើសរើសបុគ្គលិកសម្រាប់ខែមករា ឆ្នាំ២០១៥ ដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ [ទំព័រ ៩]

## y កំសាន្ត និងប្រាជ្ញា

❑ ល្បែងស្វែងរកពាក្យ ល្បែងផ្គុំឈើគូស ល្បែងសូដូគុ ល្បែងស្វែងរកចំណុចខុសគ្នា [ទំព័រ ១៦]

❀ចំណងជើងក្របមុខ៖ វេទិកាការងាររបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥

❀ចំណងជើងក្របក្រោយ៖ អាសយដ្ឋានទីភ្នាក់ងារជាតិមុខរបរ និងការងារ

## ព្រឹត្តិបត្រការងារ

**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន

ឯកឧត្តម ប៉ុក ប៉ាន់

ឯកឧត្តម ឡៅ ហ៊ីម

ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក ហៃ ហ៊ុនឡេង

**និពន្ធនាយករង**

លោក គួច សុមាន

លោក ទូច សុផាត

**ការីនិពន្ធ**

លោកស្រី លី វួចចេង

លោក សុជាតិ កញ្ញារិទ្ធ

លោក ខេង សុគន្ធា

កញ្ញា អ៊ូច ជាច័ន្ទមល្លិកា

លោក ស៊ីវ យ៉ាង

លោកស្រី ឌី ចង្កុលណី

មន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ

**នាយកគ្រប់គ្រងការផ្សាយ**

លោក ប៊ុន ដារីន

**នាយកគ្រប់គ្រងការបោះពុម្ព**

លោក គឹម កែវរស្មី

**នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ**

លោក ផូវ ឧស្សាហ៍វេចនា

**អ្នករចនាអត្ថបទ**

កញ្ញា ឈា បញ្ញារី

លោក ផែន រដ្ឋា

**អ្នកពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធ**

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ

& F *



ព័ត៌មាន និងសកម្មភាព

# សកម្មភាពថ្មីៗ ពាក់ព័ន្ធនឹងវិស័យការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## ទស្សនកិច្ចស្វែងយល់ពី «សេវាការងារសាធារណៈ តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ»



កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ បានរៀបចំទទួលដំណើរទស្សនកិច្ចស្វែងយល់ពី « **សេវាការងារសាធារណៈ តាមរយៈទីភ្នាក់ងារ ជាតិមុខរបរ និងការងារ** »ដល់សហជីពចំនួន ០២ រួមមានៈ NACC និង CTU ដែលមានអ្នកចូលរួមចំនួន ១៥ នាក់ ក្រោមការឧបត្ថម្ភគាំទ្រដោយគម្រោង ILO នៅមជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ។

កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹងឲ្យកាន់តែទូលំទូលាយអំពីសេវា NEA និងការណែនាំអំពីមគ្គុទេសក៍អាជីព ជាពិសេសពង្រឹង និងពង្រីកកិច្ចសហការរវាង NEA និងសហជីព តាមរយៈមជ្ឈមណ្ឌលការងាររាជធានីភ្នំពេញដែលជាអ្នកផ្តល់សេវាដោយផ្ទាល់ក្នុងការចុះឈ្មោះស្វែងរកការងារធ្វើដល់ក្រុមយុវជនដែលមានបំណងស្វែងរកការងារធ្វើ និងកម្មសិក្សាការងារ។

តាមរយៈកម្មវិធីនេះមជ្ឈមណ្ឌលការងាររាជធានីភ្នំពេញបានទទួលលទ្ធផលដូចខាងក្រោម៖

| | |
|---|---|
| ◈ ចែកខិតប័ណ្ណផ្សព្វផ្សាយ NEA | ចំនួន ៤០០ សន្លឹក |
| ◈ ចែកឯកសារ ( Kits ) ដល់អ្នកចូលរួម | ចំនួន ១៥ ច្បាប់ |
| ◈ ចែកព្រឹត្តិបត្រការងារ | ចំនួន ១៥ ក្បាល |
| ◈ ចែកទម្រង់ចុះឈ្មោះស្វែងរកការងារធ្វើ | ចំនួន ១៥ សន្លឹក |
| ◈ ចែកទម្រង់ចុះឈ្មោះស្វែងរកឱកាសចុះកម្មសិក្សា | ចំនួន ១៥ សន្លឹក |


តទៅទំព័របន្ទាប់

# វេទិកាការងារស្តីពី «ឱកាសការងារ និងកម្មសិក្សាការងារ»



កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ ក្រោមការចង្អុលបង្ហាញពីថ្នាក់ដឹកនាំ NEA ស្របតាមយន្តការ «វេទិកាការងារ» ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការជួយស្វែងរកការងារគ្រប់ប្រភេទជូនអ្នកស្វែងរកការងារធ្វើ និងឆ្លើយតបឱ្យបានទាន់ពេលវេលានូវតម្រូវការជ្រើសរើសបុគ្គលិកយ៉ាងច្រើនសន្ធឹកសន្ធាប់របស់និយោជក ក្រុមការងារមជ្ឈមណ្ឌលការងាររាជធានីភ្នំពេញក្រោមកិច្ចសហការជាមួយផ្នែកពាក់ព័ន្ធ បានរៀបចំឱ្យមានជាវេទិកាការងារស្តីពី **«ឱកាសការងារ និងកម្មសិក្សាការងារ »** ក្នុងគោលបំណងផ្តល់ជាកន្លែងជួបគ្នាដោយងាយស្រួលរវាងនិយោជក និងអ្នកស្វែងរកការងារធ្វើ ដើម្បីបំពេញនូវតម្រូវការជ្រើសរើសកម្លាំងពលកម្ម ដោយការដាក់ពាក្យស្វែងរកការងារធ្វើ និងជួបសម្ភាសន៍នៅនឹងកន្លែងដោយផ្ទាល់។ វេទិកានេះ មានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រុមហ៊ុន សហគ្រាស ចំនួន ០៣ រួមមាន ៖ Naga Academy, KK Fund Leasing Plc និង Manulife ។

ជាលទ្ធផល វេទិកានេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- អ្នកចូលស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន ចំនួន ១១១ នាក់ (ស្រី ៤៦ នាក់)
- ចែកខិត្តប័ណ្ណផ្សព្វផ្សាយ NEA ចំនួន ១១១ សន្លឹក
- បានចែកឯកសារស្តីពី NEA សម្រាប់និយោជក ចំនួន ១០ ច្បាប់
- ចែកទម្រង់ចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ចំនួន ៥០ សន្លឹក
- ចែកទម្រង់ចុះឈ្មោះអ្នកស្វែងរកកម្មសិក្សាការងារ ចំនួន ៥០ សន្លឹក
- ទទួលបានទម្រង់ចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ចំនួន ០៥ សន្លឹក
- ទទួលបានទម្រង់ចុះឈ្មោះអ្នកស្វែងរកកម្មសិក្សា ចំនួន ០៥ សន្លឹក
- អ្នកចុះឈ្មោះសម្ភាសជាមួយក្រុមហ៊ុន ចំនួន ៧៧ នាក់ (ស្រី ២៩ នាក់)

មន្ត្រីរបស់មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ នឹងខិតខំពង្រឹងសមត្ថភាពក្នុងការបន្តរៀបចំបន្ថែមទៀត ដើម្បីសម្របសម្រួល និងផ្តល់ឱកាសឱ្យកាន់តែទូលំទូលាយសម្រាប់អ្នកស្វែងរកការងារធ្វើ ជាពិសេសយុវជនឱ្យបានជួបផ្លាស់ប្តូរយោបល់ដោយផ្ទាល់ជាមួយនិយោជក ដើម្បីស្វែងយល់កាន់តែច្បាស់ពីលក្ខខណ្ឌ តម្រូវការជំនាញ និងបទពិសោធន៍ផ្សេងៗក្នុងការត្រៀមខ្លួនចូលទីផ្សារការងារប្រកបដោយភាពជោគជ័យ។


តទៅទំព័របន្ទាប់

# កិច្ចសម្ភាសការងារប្រចាំសប្តាហ៍

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ បានអញ្ជើញតំណាង **អង្គការ រីដា** (REDA) ដើម្បីចូលរួម **កិច្ចសម្ភាសការងារប្រចាំសប្តាហ៍** ក្នុងគោលបំណងផ្តល់ជាកន្លែងជួបគ្នាដោយងាយស្រួលរវាងនិយោជក និងអ្នកស្វែងរកការងារធ្វើ ដើម្បីបំពេញនូវតម្រូវការជ្រើសរើសកម្លាំងពលកម្ម ដោយការដាក់ពាក្យស្វែងរកការងារធ្វើ និងជួបសម្ភាសន៍នៅនឹងកន្លែងដោយផ្ទាល់។

ជាលទ្ធផល កម្មវិធីនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- **អ្នកចូលសម្ភាសការងារ** **ចំនួន ២២ នាក់ (ស្រី ១៦)**
- **អ្នកទទួលបានការងារតាមរយៈកម្មវិធី** **ចំនួន ០៦ នាក់ (ស្រី ០៤)**
- **បែកខិត្តប័ណ្ណផ្សព្វផ្សាយ NEA** **ចំនួន ២២ សន្លឹក**
- **បានចែកឯកសារស្តីពី NEA សម្រាប់និយោជក** **ចំនួន ០២ ច្បាប់**

មន្ត្រីរបស់មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ នឹងបន្តរៀបចំកម្មវិធីនេះបន្ថែមទៀត ដើម្បីសម្របសម្រួល និងផ្តល់ឱកាសឱ្យកាន់តែទូលំទូលាយសម្រាប់អ្នកស្វែងរកការងារធ្វើ ជាពិសេសយុវជនឱ្យបានជួបសម្ភាសដោយផ្ទាល់ជាមួយនិយោជក ដើម្បីស្វែងយល់កាន់តែច្បាស់ពីលក្ខខណ្ឌតម្រូវការជំនាញ និងបទពិសោធន៍ផ្សេងៗ ក្នុងការចូលទីផ្សារការងារប្រកបដោយភាពជោគជ័យ។

# កិច្ចប្រជុំបូកសរុបការងាររបស់ ទ.ជ.ម.ក ប្រចាំខែមករា

កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្នាក់ការកណ្តាលរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) មានកិច្ចប្រជុំបូកសរុបការងារប្រចាំខែវិច្ឆិកា ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយមានការចូលរួមពីប្រធានមជ្ឈមណ្ឌលការងារទាំង ០៧ តាមរយៈ Skype និងមន្ត្រីរាជការនៅថ្នាក់កណ្តាលទាំងអស់។

## កិច្ចប្រជុំបូកសរុបការងារសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយឯកសារគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី នៅសណ្ឋាគារឡឺរ៉ូយ៉ាល់
- បានទទួលជួបពិភាក្សាជាមួយលោកស្រីបណ្ឌិត Alexandra Gattrel អ្នកជំនាញផ្នែកស្រាវជ្រាវមកពីសកលវិទ្យាល័យម៉ូណាស នៅប្រទេសអូស្ត្រាលី និងលោក **សេង គ្រឹះស្នា** អ្នកដឹកនាំស្រាវជ្រាវក្នុងតំបន់/ស្រុក ស្តីពីការអនុវត្តនូវការអភិវឌ្ឍការដាក់បញ្ចូលពិការភាពក្នុងវិស័យការងារ។
- បានចូលរួមជួបប្រជុំពិភាក្សាការងារជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អំពីស្ថានភាពទាក់ទងទៅនឹងការអនុវត្តសិទ្ធិមនុស្សក្នុងវិស័យការងារ។
- បានចូលរួមប្រជុំពិភាក្សាលើចំណុចខ្លាំង ចំណុចខ្សោយឱកាស និងការគំរាមកំហែងក្នុងសមិទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងកែសម្រួលចក្ខុវិស័យផែនការសកម្មភាពឆ្នាំ២០១៥-២០១៧ របស់ ទ.ជ.ម.ក។
- បានចូលរួមប្រជុំស្តីពីការបែងចែកប្រាក់រង្វាន់សម្រាប់ឆ្នាំ២០១៥ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- បានចូលរួមបគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសម្ថភាពការដោះស្រាយវិវាទការងារ ការទប់ស្កាត់ និងដោះស្រាយជូដកម្ម បាតុកម្ម។
- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពីការចែករំលែកបទពិសោធន៍អំពីការអភិវឌ្ឍធនធានមនុស្ស ដើម្បីការងារសមរម្យ និងការងារសង្គម នៃប្រទេសជប៉ុន និងប្រទេសឥណ្ឌូនេស៊ី។
- បានចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍ និងចំណេះដឹងពីប្រទេសជប៉ុន

- បានចូលរួមសិក្ខាសាលាស្តីពីការផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវលើកំណែទម្រង់កម្មវិធីសិក្សាមធ្យមសិក្សាបំណោះទូទៅ នៅកម្ពុជា
- បានចូលរួមអមឯកឧត្តមរដ្ឋមន្ត្រី ក្នុងដំណើរទស្សកិច្ចនៅក្រុមហ៊ុន ស៊ូព្រីម ធេលីខមមូនីខេសិន មេឌា គ្រុប (ខេមបូឌា) ខូ អិលធីឌី និងពិភាក្សាកិច្ចសហប្រតិបត្តិការពីការបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ប្រធានបទការលើកកម្ពស់ការងារក្នុងស្រុក
- បានចូលរួមអមឯកឧត្តមរដ្ឋមន្ត្រី ជួបសម្តែងការគួរសម និងសំណេះសំណាលជាមួយគណៈប្រតិភូសហព័ន្ធ សហជីពចិន (ACFTU)

បន្ទាប់ពីការធ្វើរបាយការណ៍របស់មជ្ឈមណ្ឌលការងារទាំង០៧ ផ្នែកទាំង០៤ និងក្រុមការងារនីមួយៗរួចមក ឯកឧត្តមប្រធានបានផ្តល់អនុសាសន៍ និងផ្តល់ដំណោះស្រាយទៅលើបញ្ហាប្រឈមដែលកំពុងមានផងដែរ។ ជាចុងក្រោយលោកឯកឧត្តមប្រធានបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការអនុវត្តការងារដែលសម្រេចបានកន្លងមក និងសំណូមពរឱ្យមន្ត្រីរាជការទាំងអស់បន្តនូវធន្ទៈពុះពារអនុវត្តការងារឱ្យបានខ្លាំងក្លាបន្ថែមទៀត ដើម្បីចូលរួមចំណែកទាំងអស់គ្នាសម្រេចឱ្យបាននូវផែនការអនុវត្តការងារប្រចាំឆ្នាំ២០១៤នេះ៕



ព័ត៌មានទីផ្សារការងារ

# ព័ត៌មានទីផ្សារការងារនៅកម្ពុជា

## ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរនិងការងារ ពីខែមីនា ឆ្នាំ២០១០ ដល់ ខែធ្នូ ឆ្នាំ២០១៤

អត្ថបទនេះមានបំណងបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងពេលបច្ចុប្បន្ន ក្នុងទីផ្សារការងារកម្ពុជា តាមរយៈទិន្នន័យស្ថិតិអ្នកចុះឈ្មោះស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) ចាប់ពីខែមីនា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១៤។ ទិន្នន័យទាំងនោះរួមមាន អ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន២៤.៧៨២នាក់ (មិនរួមបញ្ចូលអ្នកស្វែងរកការងារធ្វើ ដែលបានប្រមូលនៅតាមមូលដ្ឋាន) និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ១៩៩.៧៦៣នាក់។ ជាថ្មីម្តងទៀត ទ.ជ.ម.ក សូមបញ្ជាក់ថា ទិន្នន័យដែលបាន និងកំពុងលើកយកមកបង្ហាញជូនក្នុងផ្នែកនេះ គឺមិនគ្របដណ្តប់លើទិន្នន័យសម្រាប់ប្រទេសកម្ពុជាទាំងមូលទេ ដូច្នេះរាល់ការប្រើប្រាស់ និងការបកស្រាយទិន្នន័យទាំងនេះ ត្រូវពិចារណានូវបញ្ហានេះ។

### ១. ចំនួនអ្នកស្វែងរកការងារធ្វើនិងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមីនា ឆ្នាំ២០១០ - ខែវិច្ឆិកា ឆ្នាំ២០១៤)

ដើម្បីធ្វើការបង្ហាញអំពីស្ថានភាពទីផ្សារការងារមួយ យើងចាំបាច់ត្រូវតែធ្វើការពិចារណាទៅលើតម្រូវការ និងការផ្គត់ផ្គង់នៃកម្លាំងពលកម្មនៅក្នុងទីផ្សារនេះ។ ប៉ុន្តែការវិភាគ ពិចារណាពីកម្លាំងពលកម្មអាចធ្វើឡើងក្នុងទម្រង់ និងរូបភាពច្រើនសណ្ឋាន។ ក្នុងចំនុចនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) សូមលើកយកការប្រៀបធៀបរវាងចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ (ISCO) មកធ្វើការបង្ហាញជូន។ បើពិនិត្យមើលទៅលើក្រុមចំណាត់ថ្នាក់មុខរបរធំបំផុត (Major Occupation) ដែលបានបង្ហាញជូនក្នុងរូបទី១(ទំព័របន្ទាប់) ឃើញថាក្រុមដែលមានការផ្គត់ផ្គង់កម្លាំងពលកម្មច្រើនជាងគេ គឺក្រុមអ្នកជំនាញឯកទេសវិជ្ជាជីវៈដែលមានអត្រារហូតដល់ ៣២,៧% នៃចំនួនអ្នកស្វែងរកការងារធ្វើសរុបដែលប្រមូលដោយទីភ្នាក់ងារ ជាតិមុខរបរ និងការងារ ចំណែកតម្រូវការកម្លាំងពលកម្មសម្រាប់ក្រុមជំនាញដូចគ្នានេះ គឺមានត្រឹមតែ ១១,៦% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើផ្នែកតម្រូវការកម្លាំងពលកម្មវិញឃើញថាក្រុមដែលមានតម្រូវការខ្ពស់ជាងគេ គឺកម្មករជំនាញផ្នែកសិប្បកម្ម និងកម្មករជំនាញពាក់ព័ន្ធ ដែលមានអត្រារហូតដល់៣៧,៦% នៃតម្រូវការកម្លាំងពលកម្មសរុបដែលបានប្រមូលដោយ ទ.ជ.ម.ក រីឯការផ្គត់ផ្គង់សម្រាប់ក្រុមចំណាត់ថ្នាក់មុខរបរដូចគ្នានេះមានត្រឹមតែ ៩,៨% ប៉ុណ្ណោះ។


តទៅទំព័របន្ទាប់

រូបទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមីនា ឆ្នាំ២០១០ - ខែធ្នូ ឆ្នាំ២០១៤)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.៧៨២នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ១៩៩.៧៦៣នាក់

## ២. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ - ខែធ្នូ ឆ្នាំ២០១៤)

បើពិនិត្យមើលទៅលើចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកទៅតាមវិស័យធំៗទាំងបីនៃសកម្មភាពសេដ្ឋកិច្ច យើងចាប់អារម្មណ៍ឃើញថាទាំងតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម គឺបានប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម និងតាមពីក្រោយរៀងគ្នាដោយវិស័យឧស្សាហកម្ម និងកសិកម្ម(រូបទី២)។ ក្នុងនោះ យើងសង្កេតឃើញថានៅក្នុងវិស័យសេវាកម្ម ចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មានអត្រា ៦៤,៨% ខ្ពស់ជាងព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម)ដែលមានអត្រា៤៥,៩%ប៉ុណ្ណោះ។ ចំណែកឯវិស័យឧស្សាហកម្មវិញ ឃើញថាព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) មានអត្រាប្រហែល ៥១,២% ចំណែកឯចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) ក្នុងវិស័យនេះវិញមានអត្រាត្រឹមតែ ១៩,១% ប៉ុណ្ណោះ។

រូបទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមវិស័យសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ ខែធ្នូ ឆ្នាំ២០១៤)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.៧៨២នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ១៩៩.៧៦៣នាក់

តារាងទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច
(ខែមីនា ឆ្នាំ២០១០ - ខែធ្នូ ឆ្នាំ២០១៤)

| ចំណាត់ថ្នាក់នៃសហគ្រាស | | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| A | កសិកម្ម និងរុក្ខាប្រមាញ់ | 507 | 2.0 | 4,341 | 2.2 |
| B | រ៉ែ និងថ្ម | 21 | 0.1 | 196 | 0.1 |
| C | កម្មន្តសាល | 3,541 | 14.3 | 96,477 | 48.3 |
| D | អគ្គិសនី ឧស្ម័ន ចំហាយ និងផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | 1,073 | 4.3 | 5,470 | 2.7 |
| E | ផ្គត់ផ្គង់ទឹក លូទឹក គ្រប់គ្រងសំរាម និងសកម្មភាពផ្សេងៗ | 89 | 0.4 | 133 | 0.1 |
| F | សំណង់ | 406 | 1.6 | 3,222 | 1.6 |
| G | លក់ដុំ និងរាយ | 1,540 | 6.2 | 8,854 | 4.4 |
| H | ដឹកជញ្ជូន ស្តុក និងឃ្លាំង | 201 | 0.8 | 658 | 0.3 |
| I | សណ្ឋាគារ ការស្នាក់អាស្រ័យ អាហារ ភេសជ្ជៈ និងសេវាផ្សេងៗ | 1,681 | 6.8 | 14,918 | 7.5 |
| J | ព័ត៌មាន និងទូរគមនាគមន៍ | 1,459 | 5.9 | 7,048 | 3.5 |
| K | ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 3,823 | 15.4 | 13,782 | 6.9 |
| L | អចលនទ្រព្យ | 52 | 0.2 | 465 | 0.2 |
| M | វិជ្ជាជីវៈ បច្ចេកទេស និងវិទ្យាសាស្ត្រ | 1,942 | 7.8 | 3,377 | 1.7 |
| N | រដ្ឋបាល និងសេវាគាំទ្រ | 810 | 3.3 | 3,824 | 1.9 |
| O | រដ្ឋបាលសាធារណៈ និងការពារ | 325 | 1.3 | 1,935 | 1.0 |
| P | អប់រំ | 1,525 | 6.2 | 11,203 | 5.6 |
| Q | សុខភាព និងសេវាសង្គម | 569 | 2.3 | 3,849 | 1.9 |
| R | សិល្បៈ ការកំសាន្ត និងការច្នៃប្រឌិត | 59 | 0.2 | 3,319 | 1.7 |
| S | សេវាផ្សេងៗ | 1,310 | 5.3 | 12,765 | 6.4 |
| T | សកម្មភាពជានិយោជកនៅក្នុងផ្ទះដោយប្រកបអាជីវកម្ម ឬសេវាផ្សេងៗ | 39 | 0.2 | 176 | 0.1 |
| U | សកម្មភាពរបស់ស្ថានទូត កុងស៊ុល និងអង្គការអន្តរជាតិ | 314 | 1.3 | 2,273 | 1.1 |
| V | ផ្សេងៗ | 3,495 | 14.1 | 1,478 | 0.7 |
| សរុប | | 24,782 | 100.0 | 199,763 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.៧៨២នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ១៩៩.៧៦៣នាក់

## ៣. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំបណ្តុះបណ្តាល (ខែមីនា ឆ្នាំ២០១០ - ខែធ្នូ ឆ្នាំ២០១៤)

ដោយផ្អែកលើទិន្នន័យ នៃចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយបែងចែកតាមកម្រិតអប់រំ (រូបទី៣) ឃើញថាអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មួយភាគធំ ប្រមាណជា ៥៩,៧% កាន់សញ្ញាបត្របរិញ្ញាបត្រ ចំណែកឯព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) កម្រិតបរិញ្ញាបត្រវិញមានត្រឹមតែ ១៦,២% ប៉ុណ្ណោះ។ បើ ពិនិត្យមើលទៅលើព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម)វិញឃើញថា តម្រូវការកម្លាំងពលកម្មមួយភាគធំ គឺមិនទាមទារឱ្យមានបញ្ចប់ថ្នាក់សិក្សាណាមួយឡើយ ដែលមានអត្រារហូតដល់ ៦៣,៨% ដែលជាអត្រាមួយខ្ពស់ខ្លាំង បើប្រៀបធៀបជាមួយនឹងចំនួនអ្នកស្វែងរកការងារធ្វើ ដែលមានកម្រិតអប់រំដូចគ្នានេះមានត្រឹមតែ១៤,៣%។

រូបទី៣ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមកម្រិតអប់រំបណ្តុះបណ្តាល (ខែមីនា ឆ្នាំ២០១០ - ខែធ្នូ ឆ្នាំ២០១៤)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.៧៨២នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ១៩៩.៧៦៣នាក់

*អត្ថបទស្តីពី ព័ត៌មានទីផ្សារការងារនៅកម្ពុជា រៀបចំ និងបកស្រាយពន្យល់ដោយលោក **តួច សុមាន** (អនុប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ) និង កញ្ញា **អ៊ឹង ច័ន្ទនារី** (មន្ត្រីស្ម័គ្រចិត្ត ទីភ្នាក់ងារជាតិមុខរបរ និងការងារ) យោងតាមមូលដ្ឋានទិន្នន័យដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ។*

& *



ព័ត៌មានជ្រើសរើសបុគ្គលិក

# ព័ត៌មានជ្រើសរើសបុគ្គលិក

VACANCY ANNOUNCEMENT

លោកអ្នកដែលមានបំណងដាក់ពាក្យសុំការងារ និងចង់ដឹងព័ត៌មានអំពីឱកាសការងារជាច្រើនប្រភេទផ្សេងទៀតអាចទំនាក់ទំនងមកកាន់ «**មជ្ឈមណ្ឌលការងារ**» ណាមួយរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឬអាចស្វែងរក និងទាញយកព័ត៌មានទាំងអស់នេះ

**ដើម្បីទទួលបានសេវាការងារដោយ «ឥតគិតថ្លៃ» សូមទំនាក់ទំនង ឬធ្វើដំណើរមកកាន់៖**

**មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ

☎ ០២៣ ៦៣៣ ៦០០២
០៧៧ ២៣២ ៣៧៨
០១៦ ៧៨៦ ៦៥៥

✉ jc_pp@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង**

វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង
ផ្លូវលេខ ១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ
ក្រុងបាត់ដំបង

☎ ០៥៣ ៧៣៣ ១១១
០១៦ ៩២៦ ៦៥៥

✉ jc_battambang@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តសៀមរាប**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប
សង្កាត់ស្លក្រាម ក្រុងសៀមរាប

☎ ០៦៣ ២១០ ២៧៧
០១៦ ៥៣៦ ៦៥៥

✉ jc_siemreap@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តកំពត**

វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត
ភូមិ ១ ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត

☎ ០៣៣ ២១០ ២៧៧
០១៦ ៥០៦ ៦៥៥

✉ jc_kampot@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង
ភូមិមេភ្លើង សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង

☎ ០៤៤ ៧១៥ ២៧៧
០១៦ ៦៤៦ ៦៥៥

✉ jc_svayrieng@nea.gov.kh

ឥឡូវនេះ អតិថិជនរបស់ Hello អាចធ្វើការហៅចូលដោយ «ឥតគិតថ្លៃ» មកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ក្រុមហ៊ុន កម្ពុជាតេលា

**ថ្ងៃផុតកំណត់:** ១៦ កុម្ភៈ ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. គណនេយ្យករ (០១នាក់)

២. អ្នកវាយប័ណ្ណ (០១នាក់)

៣. អ្នកថែរក្សា-ជួសជុលឧបករណ៍(ម៉ូទ័រ បូម និង Flow Meter) (០១នាក់)

៤. សន្តិសុខ (០៤នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- បរិញ្ញាបត្រគណនេយ្យ
- បទពិសោធន៍ទាក់ទងនឹងការងារចំនួន ០២ឆ្នាំ
- និយាយ និងសរសេរភាសាអង់គ្លេសបានល្អ
- កម្រិតវប្បធម៌ BST គ្រឿងយន្ត
- កម្រិតវប្បធម៌ បឋមភូមិ
- មានកាយសម្បទាមាំមួន

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ២៤ ផ្លូវយោធពលខេមរភូមិន្ទ(២៧១) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

០២៣ ៨៨៥ ៥៥១

info@telapetroleum.com

## ក្រុមហ៊ុន សថាបនា (ត)

៣. អ្នកកាន់ស្តុក (ទាំងពីរភេទ)

៤. បេឡា (ភេទស្រី ០១នាក់)

៥. ប្រមូលប្រាក់ (ភេទប្រុស ០៤នាក់)

៦. ជាងជួសជុលខ្សែកាប និងជាងស្លាយអុបទិច ភេទប្រុស ០៤នាក់

៧. ជាងភ្លើង (ភេទប្រុស ០២នាក់)

៨. គណនេយ្យករ (ភេទប្រុស ០១នាក់)

៩. អ្នកកាត់តវីដេអូ (ភេទប្រុស ០២ នាក់)

១០.អ្នករៀបចំកម្មវិធីកីឡា (ភេទប្រុស ០១នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍យ៉ាងតិចមួយឆ្នាំ និងប័ណ្ណបើកបរ
- ចេះភាសាអង់គ្លេស ឬភាសាចិន និងកុំព្យូទ័រ
- មានបរិញ្ញាបត្រហិរញ្ញវត្ថុ ឬផ្នែកទីផ្សារ ឬគ្រប់គ្រង
- មានចំណេះដឹង MS Office
- មានចំណេះដឹងភាសាអង់គ្លេសអាចប្រើការបាន
- មានអាកប្បកិរិយាល្អ ស្មោះត្រង់រួសរាយរាក់ទាក់ មានភាពអំណត់ និងមានទំនួលខុសត្រូវក្នុងការងារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៨៣១C មហាវិថីព្រះមុន្នីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

០៨៥ ៥៤៧ ២៣២

job@sathapana.com.kh

## ក្រុមហ៊ុនទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ

**ថ្ងៃផុតកំណត់:** ២០ កុម្ភៈ ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើកឡាន (ភេទប្រុស ០៣នាក់)

២. អ្នកទទួលភ្ញៀវ (ភេទស្រី ០៣នាក់)

## PRASAC MFI Ltd.,

**Closing Date:** 20 February 2015

**Location:** Phnom Penh

**Job Title:**

1. VP and Manager of Operation Department ( 01 Position)

**Requirement**

- BA in Management, Finance, Accounting, or

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

banking. MBA is advantage.

- At least 5 years experience working in banking sector.
- Strong analytical skills, problem solver, and attention to detail
- Excellent interpersonal skills, combined with internal and external stakeholders and directly influence them.
- Ability to work independently and under pressure so as o meet tight and often conflicting deadlines
- Excellent communication skills, oral and written, in English and Khmer languages.

**Please contact:**

# 212, St. 271, Sangkat Tuoltom Pong II, Khan Chamkarmorn, Phnom Penh

023 220 102

info.pp@prasac.com.kh

## Catholic Relief Services (CRS)

**Closing Date:** 18 February 2015

**Location:** Phnom Penh

**Job Title:**

1. Health System Strengthening (HSS) Program Specialist (01 Position)

**Requirement**

- Master degree in Public Health or other health equivalent experience.
- At least 3 years in HSS/CSS programming management experience including program development, capacity building, monitoring and valuation, Budget management, and report writing.
- Good ability to learn new initiative/approach and adapt /roll out project implementation including community-based integration.
- Experience in health care financing including health equity fund, community-based health insurance schemes (CBHIS) and community donation including charity boxes and village saving
- Experience in local governance including commune development plan (CDP) and commune investment plan (CIP) process and its functions
- Experience in implementation of community participatory in Health including VHSGs and HCMC roles and responsibilities and its functions
- Experience working on Global Fund grants desired
- Experience of working successfully in partnership with national level institution, local partners, and staff for program implementation and capacity buildings.
- Proficiency in spoken and written English and Khmer.
- Computer literacy in MS Office.
- Ability to travel to the field at least 50% of the time

**Please contact:**

#14, St. 278 , Sangkat BKK I, Khan Chamkarmorn, Phnom Penh

kh.recruitment@crs.org

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## A & A Auto Group Co., Ltd

**Closing Date:** 28 February 2015

**Location:** Phnom Penh

**Job Title:**

1. Sales manager (01 Position)
2. Sales Consultant (06 Position)
3. Senior Accountant (01 Position)

**Requirement**

**Please contact:**

MAZA Showroom, #379, Russian Blvd, Sangkat Kakab, Khan Posenchey, Phnom Penh

hr@hgbauto.com

(+855) 095 666 048

## Cambodian League for the Promotion and Defense of Human Rights (LICADHO)

**Closing Date:** 06 March 2015

**Location:** Phnom Penh

**Job Title:**

1. Deputy Director of Monitoring (01 Position)

**Requirement**

- Requires native spoken and written fluency in Khmer
- Graduate degree in relevant field (Law, Management, Political Science…)
- At least 5 years work experience in program management and dealings with LNGOs/INGOs and government institutions
- Experience in public speaking at conferences and workshops
- Strong research and analysis skills
- Knowledge of judicial process/systems
- Demonstrated ability to undertake rapid reading and summarize key points
- Strong participatory teaching techniques and communication skills
- Excellent Khmer and English oral and written communication skills including drafting, editing and proof reading
- Demonstrated ability to lead, plan, prioritize, delegate and organize work to meet deadlines
- Demonstrated networking skills with partners and local authorities.

**Please contact:**

#16, St. 99, Phnom Penh

jadmhr@licadho-cambodia.org

## VIRTUS GROUP

**Closing Date:** 15 February 2015

**Location:** Phnom Penh

**Job Title:**

1. Finance Manager ( 01 Position)
2. Admin Manager (01 Position)
3. Mechanic/Maintenance Supervisor (01 Post)
4. Personal Assistant (01 Position)
5. Electrician (Cambodian only)
6. Personal Driver/Bodyguard (01 Position)

**Requirement**

1. Finance Manager ( 01 Position)

- 5 years experience in full financial matters, budget preparations, cost verifications, payroll
- Ability to converse in English
- Ability to prepare full financial statements
- Salary commensurate with experience and qualifications
- Ability to be located at Kampot Province
- Full Board and Lodgings

2. Admin Manager (01 Position)

- Three years experience in a full administrative matters with staff complement exceeding 200


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

people., including attendance, systems and procedures, administrative matters and ability to attend to and resolve any staff related matters
- Salary commensurate with experience and qualifications
- Ability to be located at Kampot Province
- Full Board and Lodgings

3. Mechanic/Maintenance Supervisor
- Five years minimum experience in maintenance/fixing of heavy machinery fleet-excavators, bulldozers, trucks, tractors, generations
- Ability to prepare and maintain maintenance schedule and sustainable level of spare part's
- Salary commensurate with experience and qualifications
- Ability to be located at Kampot Province
- Full Board and Lodgings

4. Personal Assistant (01 Position)
- Age: 30 to 35
- Ability to operate outside office and in field Conversant in Governmental Affaire
- Salary commensurate with experience and qualifications
- Ability to be located at Kampot Province and Travel abroad and inside Cambodia
- Full Board and Lodgings

5. Electrician (Cambodian only)
- 3 years experience in all field of building electrical supplies, generators
- Ability to converse in English
- Salary commensurate with experience and qualifications
- Ability to be located at Kampot Province
- Full Board and Lodgings

6. Personal Driver/Bodyguard (01 Position)
- Five years experience in driving 4WD
- Conversant in English
- Letter of Introduction or Certificate of Good Character
- Salary commensurate with experience and qualifications
- Ability to be located at Kampot Province
- Full Board and Lodgings

**Please contact:**

vgplantations@gmial.com

## HGB Group Co., ltd

**Closing Date:** 28 February 2015

**Location:** Phnom Penh

**Job Title:**

1. Sales manager (01 Position)
2. Sales/Customer Relation Consultant (02 Position)
3. Marketing Executive (01 Position)
4. Accountant (01 position)
5. Receptionist (01 Position)
6. Service Advisor (01 Position)

**Requirement**

**Please contact:**

MAZA Showroom, #379, Russian Blvd, Sangkat Kakab, Khan Posenchey, Phnom Penh

hr@hgbauto.com

(+855) 095 666 048

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## CROWN Beverage Cans (Cambodia) Limited

**Closing Date:** 28 February 2015
**Location:** Phnom Penh
**Job Title:**
1. Production Planner (01 Position)
2. Machinist (01 P0sition)
3. Technician (01 Position)
4. QA Inspector (01 Position)

**Requirement**
1. Production Planner (01 Position)
- Certification in business administration
- Minimum two to three years working experience in relevant fields;
- Good written and spoken English
- Conscientious, highly motivated with excellent organization, interpersonal and communications skills
- Pro

- Minimum Bachelor Degree in Civil & Structural Engineering, Agricultural, Quantity Survey or equivalent.
- At least 8 years relevant working experience in property development industry.
- Able to work under tight schedule
- Ability to handle project scheduling and big scale development, possess good communication and interpersonal skills, proficient in written and spoken English.
- Ability to speak Khmer will be an added advantage.

2. Development Manager (DM)
- Degree in Real Estate Management, Business Administration, Quantity Surveying or equivalent.
- Minimum 8 years relevant working experience in property development industry;
- Able to conduct full feasibility studies, good

PR Skills.
- Preferably with international exposure especially in Indo China.
- Ability to speak Khmer is an added advantage.

**Please contact:**
feliciayong@pcd.lion.com.my

## ActionAid

**Closing Date:** 27 February 2015
**Location:** Phnom Penh
**Job Title:**
1. Finance and Administration Assistant (01 Position)

**Requirement**
- Bachelor degree in finance/accounting or business administration or related field
- Minimum 2 years experience in similar position
- Good interpersonal skill (ability to engage well with guests, supervisor, and colleagues)
- Good sense of planning and time management
- Effective Communication and negotiation skill
- Ability to operate office machines and basic finance and accounting programmed/software
- Good team player and able to work under pressure
- Honest, integrity & trustworthy
- Ability to manage confidential information.

**Please contact:**
# 69, St. 242, Phnom Penh, Cambodia
cambodia.job@actionaid.org

 តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ក្រុមហ៊ុន V &C Import Export Co., Ltd

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកគញ្ញរប់គ្រងផ្នែកទំនិញក្នុងម៉ាត

២. អ្នកគិតលុយក្នុងម៉ាត

៣. ផ្នែកលក់ក្នុងម៉ាត

៤. អ្នកគ្រប់គ្រងភោជនីយដ្ឋាន

៥. ផ្នែកកម៉ង់ម្ហូប

៦. អ្នករត់តុ

៧. អ្នកធុងកាហ្វេ និងក្រទុកទឹកផ្លែឈើ

៨. អ្នកអនាម័យ ទាំងពីរភេទ

**លក្ខខណ្ឌជ្រើសរើស:**

១. អ្នកគញ្ញរប់គ្រងផ្នែកទំនិញក្នុងម៉ាត

- ត្រូវមានសញ្ញាបត្រផ្នែកគ្រប់គ្រង
- មានបទពិសោធន៍ផ្នែកទីផ្សារ និងសេដ្ឋកិច្ច ២ឆ្នាំឡើងទៅ

២. អ្នកគិតលុយក្នុងម៉ាត

- ត្រូវមានបទពិសោធន៍ ០១ឆ្នាំឡើងទៅ

៤. អ្នកគ្រប់គ្រងភោជនីយដ្ឋាន

- មានសញ្ញាបត្រផ្នែកគ្រប់គ្រងភោជនីយដ្ឋាន, ទេសចរណ៍
- ចេះច្រើនភាសា
- មានបទពិសោធន៍ ០២ឆ្នាំឡើងទៅ

៥. ផ្នែកកម៉ង់ម្ហូប

- ចេះច្រើនភាសា
- មានបទពិសោធន៍

៦. អ្នករត់តុ

- ធ្លាប់មានបទពិសោធន៍

៧. អ្នកធុងកាហ្វេ និងក្រទុកទឹកផ្លែឈើ

- ធ្លាប់មានបទពិសោធន៍

**សូមទំនាក់ទំនងតាមរយៈ:**

អគារលេខ ៣១០ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ រាជធានីភ្នំពេញ

☎ ០៩៧៩៨៣ ៦៣ ៦៨

## WWF-Cambodia

**Closing Date:** 27 February 2015

**Location:** Phnom Penh

**Job Title:**

1. Project Coordinator ( 01 Position)

**Requirement**

- Bachelor Degree in conservation, planning, or other related fields. A master degree is pre-ferred.
- A minimum of 8 years managing large projects and strategic work planning processes, team building, and financial management.
- Experience writing high quality reports.
- Demonstrated experiencer building highly mo-tivated teams.
- Considerable experience in developing and im-plementing strategic and tactical plans. USAID experience is highly desired.
- English Language fluency( reading, writing, speaking)

**Please contact:**

# 21, St. 322, Sangkat Beng Keng Kang I, Khan Chamkarmorn, Phnom Penh

jobwwfcam@wwfgratermekong.org



កំសាន្ត និងប្រាជ្ញា

# កំសាន្ត និង ប្រាជ្ញា

ទំព័រកំសាន្ត និងប្រាជ្ញាត្រូវបានបង្កើតឡើងក្នុងបំណងផ្តល់នូវការកំសាន្តតាមបែបល្បែងប្រាជ្ញា ដើម្បីទទួលបាននូវការរីករាយ និងបង្កើនចំណេះដូនមិត្តអ្នកអានទាំងអស់។ ព្រឹត្តិបត្រការងារសង្ឃឹមថា ទំព័រនេះអាចជួយផ្តល់ជាប្រយោជន៍ផ្នែកសតិប្រាជ្ញានិងការត្រិះរិះពិចារណា ជាពិសេស ចំពោះមិត្តអ្នកអានណា ដែលមិនធ្លាប់សាកល្បងដោះស្រាយនូវចំណោទបែបនេះពីមុនមក។

ទំព័រកំសាន្ត និងប្រាជ្ញានេះមានល្បែងផ្សេងៗដូចជាការស្វែងរកពាក្យជាភាសាអង់គ្លេស ល្បែងផ្គុំឈើគូស ការស្វែងរក ល្បែងស្វែងរកច្រកចេញ និងការធ្វើចំណោទជាលេខនព្វន្តជាដើម។ អាស្រ័យហេតុនេះសូមប្រិយមិត្តអ្នកអានទាំងអស់សាកល្បងដោះស្រាយ និងរីករាយជាមួយល្បែងល្បងប្រាជ្ញាដូចខាងក្រោម៖

## ល្បែងស្វែងរកពាក្យ

ចូរបំពេញនូវពាក្យក្នុងប្រអប់ខាងក្រោមដោយប្រើប្រាស់និយមន័យ ឬពាក្យដែលមានន័យដែលគេបានផ្តល់ឱ្យខាងក្រោម៖

Across

3. The daughter of your brother or sister.
4. The son of your uncle is your ________.
6. Male partner in a marriage
8. The female partner in a marriage.
10. The mother of your mother or father.
11. Your uncle's wife.
12. The son of your daughter is your ________.
14. The daughter of your son.

Down

1. The male parent of a child
5. A male child.
7. A female child.
9. The father of your mother or father.
13. Your aunt's husband.





តទៅទំព័របន្ទាប់

## ល្បែងផ្គុំឈើគូស

ខាងក្រោមនេះមានរូបឈើគូសដែលផ្គុំគ្នាជារាងការេចំនួនពីរ ដូចនេះសូមលោកអ្នករំកិលឈើគូសចំនួនបួនដើម ដើម្បីបង្កើតបានជារាងការេចំនួនបី។ ខាងក្រោមនេះជាឧទាហរណ៍សម្រាប់លោកអ្នក:




១. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



២. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



៣. រំកិលឈើគូសចំនួន ២ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



៤. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



៥. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



៦. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



៧. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ



៨. រំកិលឈើគូសចំនួន ១ដើម ដើម្បីឱ្យសមីការខាងក្រោមត្រឹមត្រូវ




តទៅទំព័របន្ទាប់

## ល្បែងស្វែងរកពាក្យ

សូមធ្វើការស្វែងរកពាក្យខាងក្រោម៖

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| J | D | V | T | Z | R | Y | R | R | E | H | C | U |
| Z | B | S | H | U | Y | T | S | L | N | N | E | M |
| M | G | D | B | C | N | J | P | P | I | M | I | D |
| Q | R | B | P | M | A | P | L | E | R | C | Q | P |
| C | E | M | O | C | A | E | R | P | A | U | K | O |
| R | E | P | P | S | Y | I | P | Y | T | Q | C | X |
| O | I | D | L | M | F | N | K | C | C | N | M | E |
| G | G | W | A | L | N | U | T | T | E | I | W | N |
| P | N | Q | R | R | X | B | H | Y | N | O | H | J |
| R | A | E | P | P | I | M | C | X | L | M | P | L |
| L | Y | J | E | L | V | L | R | L | Q | A | N | T |
| C | H | H | N | U | E | E | I | R | L | U | C | S |
| G | Q | T | F | M | F | W | B | M | Z | O | A | K |

Apple, Birch, Cedar, Cherry, Elm, Fir, Maple, Nectarine, Oak, Palm, Peach, Pear, Plum, Pine, Poplar, Rubber, Spruce, Walnut, Willow

## ល្បែងសូដូកុ

ចូរបំពេញនូវការេនីមួយៗដែលធ្វើឱ្យជួរដេក និងជួរឈរព្រមទាំងប្រអប់ទាំង៣X៣ មានលេខរៀងគ្នាពី១ ដល់៩ ៖

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | 1 | | | | 5 | 6 |
| | | | | | | | | 7 |
| 3 | | | | | 8 | | | |
| 2 | | 9 | | | | | | |
| | | | | 6 | | | | 4 |
| 8 | | | 5 | | | | | |
| | | 4 | | | | | | |
| | | | | | 2 | 8 | | |
| | | 6 | | | | | | 5 |

## ល្បែងសូដូគុ

សិក្សាពីគំរូលេខទាំងពីរជួរខាងលើគេ រួចធ្វើការបំពេញនូវចន្លោះលេខលេខឯទៀតដែលខ្វះខាតទាំងនោះ

| | | | | | | |
|---|---|---|---|---|---|---|
| | | 12 | 23 | 34 | | |
| | 11 | 22 | 33 | | | |
| 25 | | 47 | | | | |
| | | | | | 64 | |
| | | | | 41 | | |

## ល្បែងស្វែងរកផ្លូវ

ចូរស្វែងរកផ្លូវដោយប្រើប្រាស់នូវរូបខាងក្រោម ដើម្បីនាំយកដុំទឹកកកនៅក្នុងរូបបានទៅដល់គោលដៅ៖



## ចម្លើយកំសាន្ត និងប្រាជ្ញា (ក្នុងការផ្សាយលេខ ៤០)



| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| E | D | E | Y | A | B | S | D | E | N | S | E | L | W |
| V | O | L | L | E | Y | T | N | E | H | S | A | S | A |
| L | G | U | L | C | H | N | I | D | K | N | T | S | N |
| O | D | I | U | A | Y | E | G | V | O | U | Y | O | D |
| V | E | L | F | L | D | M | H | I | B | O | D | E | E |
| E | P | A | N | P | E | N | T | E | B | L | R | S | R |
| R | O | M | I | K | E | I | R | M | S | O | E | R | S |
| S | H | E | A | R | S | A | D | I | T | O | S | E | E |
| E | D | S | P | O | U | T | S | S | E | R | P | T | D |
| C | E | P | P | W | N | R | B | S | B | D | U | U | O |
| I | R | O | B | O | T | E | L | I | A | R | R | E | R |
| D | R | E | U | Q | I | T | U | O | B | R | S | N | R |
| P | A | M | W | V | D | N | S | N | O | R | O | M | O |
| X | J | S | B | S | Y | E | H | T | R | I | G | M | C |



| | | | | | | |
|---|---|---|---|---|---|---|
| | | 5 | 9 | 13 | | |
| | 8 | 6 | 5 | 4 | 2 | |
| 4 | 3 | 4 | 5 | 5 | 8 | 10 |
| | 8 | 2 | 6 | 5 | 9 | |
| | | 9 | 10 | 11 | | |


# ទីភ្នាក់ងារជាតិមុខរបរ និងការងារ
## មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ

## វគ្គបណ្តុះបណ្តាលស្តីពី "របៀបសរសេរប្រវត្តិរូបសង្ខេប លិខិតអម និងការត្រៀមខ្លួនសម្ភាសន៍ការងារ"

តាមរយៈសិក្ខាសាលានេះអ្នកនឹងទទួលបាននូវ៖

- ចំណេះដឹង និងវិធីសាស្ត្រនៃការស្វែងរកការងារធ្វើ
- បែបបទក្នុងការរៀបចំប្រវត្តិរូបសង្ខេប និងលិខិតអម
- ការរៀបចំឥរិយាបថសម្រាប់ត្រៀមខ្លួនមុនសម្ភាសន៍ការងារ
- ទទួលបានការប្រឹក្សាយោបល់អំពីឱកាសការងារ
- ព័ត៌មានទីផ្សារការងារ

ចូលរួមដោយ
# ឥតគិតថ្លៃ!

កាលបរិច្ឆេទៈ រៀងរាល់ថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍
វេលាម៉ោង ០៩:០០ - ១១:០០ ព្រឹក
ចូលរួមដោយសេរី (សម្រាប់២៥នាក់)

*ព័ត៌មានបន្ថែមសូមទំនាក់ទំនង:*
មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ស្ថិតក្នុងបរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
ទូរស័ព្ទលេខ: ០២៣ ៦៣៣ ៦០០២ អ៊ីម៉ែល: jc_pp@nea.gov.kh ឬគេហទំព័រ: www.nea.gov.kh

# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
# Ministry of Labour and Vocational Training
# វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
# National Polytechnic Institute of Cambodia

## មានបណ្តុះបណ្តាលលើជំនាញ

- វិទ្យាសាស្ត្រកុំព្យូទ័រ
- ភាសាកូរ៉េ
- សំណង់ស៊ីវិល
- អក្សរសាស្ត្រអង់គ្លេស
- អេឡិចត្រូនិក
- វិជ្ជាជីវៈគណនេយ្យ
- មេកានិក
- គ្រប់គ្រងបច្ចេកវិទ្យា
- អគ្គិសនី
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

## យើងត្រូវតែឈានមុខគេ

### អាហារូបករណ៍ពិសេស

និទ្ទេស A : ទទួលបានអាហារូបករណ៍ ១០០%
និទ្ទេស B : ទទួលបានអាហារូបករណ៍ ៥០%
និទ្ទេស C : ទទួលបានអាហារូបករណ៍ ៣០%

និស្សិតស្រី : ទទួលបានការបញ្ចុះតម្លៃ ៣០%
និស្សិតលេខ ១ : ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ១០០%
និស្សិតលេខ ២ : ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ៣០%

### ម៉ោងសិក្សា

- ថ្ងៃចន្ទ ដល់ សុក្រ (០៨.០០_១២.០០ និង ១៣.០០_១៦.០០)
- ថ្នាក់បន្តវិស្វករ ឬបរិញ្ញាបត្របច្ចេកវិទ្យា
  ថ្ងៃសៅរ៍_អាទិត្យ ០៨.០០_១២.០០ និង ១៣.០០_១៧.០០
- មហាវិទ្យាល័យវិទ្យាសាស្ត្រកុំព្យូទ័រ និងមហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច
  វេនព្រឹក ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ០៨.០០_១២.៣០
  វេនរសៀល ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ១៣.០០_១៧.៣០

- មានបំពាក់ប្រព័ន្ធ អ៊ិនធើណេត និង FWi គ្របដណ្តប់ក្នុងបរិវេណរបស់វិទ្យាស្ថានសម្រាប់និស្សិតសិក្សាស្រាវជ្រាវ ។
- មានអ្នកជំនាញការជាតិ និងអន្តរជាតិ ។ នៅគ្រប់មហាវិទ្យាល័យ ។
- សាស្ត្រាចារ្យខ្មែរមានសញ្ញាបត្រ អនុបណ្ឌិត, បណ្ឌិត និងបទពិសោធន៍យូរឆ្នាំ ។
- រាល់កម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារ ស្តង់ដាជាតិ និងអន្តរជាតិ ។
- បន្ទប់ពិសោធន៍ និងអនុវត្តន៍មានឧបករណ៍សម្ភារៈប្រើប្រាស់តាមបច្ចេកវិទ្យាទំនើប ។

### អាសយដ្ឋាន

ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ
(023) 96 15 193 / 010 970 351 / 012 381 246 / 011 769 003
npicinfo@gmail.com
www.npic.edu.kh

### ពិធីសម្ពោធអាគារសិក្សា Hyundai-KOICA Dream Center នៅ NPIC

កាលពីថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៥ នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាបានប្រារព្ធពិធីដាក់សម្ពោធឲ្យប្រើប្រាស់នូវអាគារសិក្សាផ្នែកជួសជុលរថយន្តក្រោមជំនួយ និងកិច្ចសហប្រតិបត្តិការរវាង អង្គការ Koica, Plan, Hyundai, NPIC ក្រោមអធិបតីភាព ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមជាមួយអ្នកតំណាងរបស់ម្ចាស់ជំនួយទាំងអស់ចូលរួមផងដែរ ។ អាគារសិក្សាផ្នែករថយន្តថ្មីនេះជាកន្លែងអប់រំដ៏សំខាន់មួយដែលអាចផ្តល់ឱកាសដល់សិស្សកម្ពុជាដែលប្រឡងធ្លាក់បាក់ឌុប ឬក៏សិស្សដែលគ្មានលទ្ធភាពបន្តការសិក្សាថ្នាក់មហាវិទ្យាល័យ ដើម្បីទទួលបានចំណេះដឹងជំនាញច្បាស់លាស់ ហើយអាចចូលរួមអភិវឌ្ឍន៍សង្គមកម្ពុជាដែលកំពុងមានតម្រូវការអ្នកបច្ចេកទេសយ៉ាងច្រើនក្នុងពេលបច្ចុប្បន្ន





### ពិធីប្រកួត Robot របស់និស្សិតមហាវិទ្យាល័យមេកានិកនៃវិទ្យាស្ថាន NPIC

និស្សិតវិទ្យាស្ថានជាតិ NPIC ក្រោមការបណ្តុះបណ្តាលពីនិស្សិត និងសាស្ត្រាចារ្យរបស់សាកលវិទ្យាល័យ Koreatech បានធ្វើការប្រកួតប្រជែង ROBOT ប្រចាំមហាវិទ្យាល័យមេកានិកជាលើកដំបូងកាលពីថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៥ ដែលមានអ្នកសារព័ត៌មានជាតិ និងទូរទស្សន៍ជាច្រើនចូលរួមថតយករូបភាព និងសកម្មភាពប្រកួតប្រជែងដើម្បីយកទៅចាក់ផ្សាយនៅស្ថានីយ៍របស់ខ្លួន ។ ជាការជំរុញ និងលើកទឹកចិត្តដល់ក្រុមនិស្សិតដែលបានចូលរួមប្រកួតទាំងអស់ ឯកឧត្តម ប៊ុន ភារិន នាយកវិទ្យាស្ថាន NPIC បានមានប្រសាសន៍ថា នេះជាសកម្មភាពសិក្សារបស់និស្សិតវិទ្យាស្ថានខាងផ្នែកទ្រឹស្តីហើយភ្ជាប់ជាមួយការអនុវត្តន៍ជាក់ស្តែង ។ ជាងនេះទៅទៀតដើម្បីទទួលបានចំណេះដឹង និងជំនាញច្បាស់លាស់ណាមួយនោះ និស្សិតខ្លួនឯងផ្ទាល់ត្រូវខិតខំសិក្សាស្រាវជ្រាវរៀនបន្ថែមដោយខ្លួនឯងទៀតក្រៅពីការសិក្សានៅសាលា ។





### សិក្ខាសាលាអន្តរជាតិស្តីពី "បច្ចេកវិទ្យាគ្រប់គ្រងទឹកស្អាតអោយមាននិរន្តរភាព" បានប្រារព្ធធ្វើនៅវិទ្យាស្ថាន NPIC

វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា រួមជាមួយដៃគូសហប្រតិបត្តិការអន្តរជាតិមកពីប្រទេស ជប៉ុន កូរ៉េ សហគមន៍អឺរ៉ុប បានរួមគ្នាធ្វើសិក្ខាសាលាស្តីពី បច្ចេកវិទ្យាគ្រប់គ្រងទឹកស្អាតអោយមាននិរន្តរភាព ដែលបានរៀបចំនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ចាប់ពីថ្ងៃទី ១១ ដល់ ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ។ សិក្ខាសាលានេះមានរយៈពេល ២ថ្ងៃ ក្រោមអធិបតីភាព ឯកឧត្តម ប៊ុន ភារិន នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា និង លោក Kill Su Park ប្រធានគ្រប់គ្រង ស្រាវជ្រាវ ផ្គត់ផ្គង់ និងចែកចាយទឹកថ្នាក់ជាតិរបស់ប្រទេសកូរ៉េខាងត្បូង ។ គោលបំណងសំខាន់ចំបងក្នុងការរួមគ្នាបង្កើតសិក្ខាសាលានេះឡើងគឺ ដើម្បីផ្លាស់ប្តូរចែករំលែកចំណេះដឹង បទពិសោធន៍ទាក់ទងនឹងការប្រើប្រាស់ទឹកនៅក្នុងពិភពលោកអោយបានយូរអង្វែង និងចូលរួមកាត់បន្ថយរាល់បញ្ហាដែលផ្តល់ផលប៉ះពាល់ទៅលើទឹកនៅក្នុងពិភពលោកទាំងមូល ។






សូមមេត្តារង់ចាំទស្សនា
នាទី
ទីផ្សារការងារ និង មុខរបរ
នៅលើកញ្ចក់ទូរទស្សន៍
អង្គារ 22h
ពុធ 17h
សុក្រ 10h:45mn
សុក្រ 10h
សៅរ៍ 11h
សៅរ៍ 11h
សៅរ៍ 12h
សៅរ៍ 14h
សៅរ៍/អាទិត្យ 13h
អាទិត្យ 10h/17h
ឬលើគេហទំព័រ
www.nea.gov.kh

## ដៃគូសហការសំខាន់ៗ

ត្រូវការ

# ការងារ ឬ បុគ្គលិក

## សេវាសម្រាប់ អ្នកស្វែងរកការងារធ្វើ

- ការចុះឈ្មោះស្វែងរកការងារធ្វើ និងផ្សព្វផ្សាយប្រវត្តិរូបសង្ខេបដោយងាយស្រួល និងទូលំទូលាយ
- ព័ត៌មានជ្រើសរើសបុគ្គលិក និងការអប់រំបណ្តុះបណ្តាលគ្រប់ប្រភេទ
- ការជួយស្វែងរកការងារធ្វើគ្រប់ប្រភេទ និងទូលំទូលាយជាងគេបំផុត
- ការផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក
- ការណែនាំអំពីឱកាសការងារ និងការវាយតម្លៃអំពីលទ្ធភាពទទួលបានការងារ
- ការណែនាំអំពីការត្រៀមលក្ខណៈស្វែងរកការងារធ្វើ ឱកាសការងារ និងការអភិវឌ្ឍអាជីព
- ព័ត៌មានទីផ្សារការងារទូទៅ

## សេវាសម្រាប់ និយោជក

- ការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិកដោយងាយស្រួល និងបានទូលំទូលាយជាងគេបំផុត
- ការផ្តល់ធនាគារទិន្នន័យអំពីអ្នកស្វែងរកការងារធ្វើគ្រប់ប្រភេទ និងច្រើនជាងគេបំផុត
- ការផ្តល់ទីតាំងការិយាល័យសម្រាប់ជ្រើសរើសបុគ្គលិក
- ការផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើគ្រប់ប្រភេទដោយងាយស្រួល
- ការចុះដល់ទីកន្លែងរបស់និយោជកផ្ទាល់ដើម្បីប្រមូលព័ត៌មានជ្រើសរើសបុគ្គលិក
- ការណែនាំអំពីការជ្រើសរើសបុគ្គលិក
- ព័ត៌មានទីផ្សារការងារទូទៅ

ផ្តល់សេវាដោយ **ឥតគិតថ្លៃ**

សូមចូលមើលគេហទំព័រ

# www.nea.gov.kh

www.facebook.com/neakhmer

យើងខ្ញុំមានមន្ត្រីរង់ចាំផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ការងារខ្ពស់!


អាសយដ្ឋានស្ថិតក្នុងបរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

០២៣ ៨៨៨ ៦៩២ ឬ ០៨៨ ៦៧៨ ៩៦៧៨ info@nea.gov.kh


សូមធ្វើការទាក់ទង


**ម.ក. រាជធានីភ្នំពេញ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
០២៣ ៦៣៣ ៦០០២ ឬ
០៧៧ ២៣៦ ៣៧៨ ឬ០១៦ ៧៨៦៦៥៥
jc_pp@nea.gov.kh

**ម.ក. ខេត្តបាត់ដំបង**

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
បាត់ដំបង ផ្លូវលេខ១០១ ភូមិព្រែកមហាទេព
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
០៥៣ ៧៣៣ ១១១
ឬ ០១៦ ៩២៦ ៦៥៥
jc_battambang@nea.gov.kh

**ម.ក. ខេត្តសៀមរាប**

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
សៀមរាប សង្កាត់ស្លក្រាម ក្រុងសៀមរាប
០៦៣ ២១០ ២៧៧
ឬ ០១៦ ៥៣៦ ៦៥៥
jc_siemreap@nea.gov.kh

**ម.ក. ខេត្តកំពត**

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត
ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត
០៣៣ ២១០ ២៧៧
ឬ ០១៦ ៥០៦ ៦៥៥
jc_kampot@nea.gov.kh

**ម.ក. ខេត្តស្វាយរៀង**

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
ស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង
០៤៤ ៧១៥ ២៧៧
ឬ ០១៦ ៦៤៦ ៦៥៥
jc_svayrieng@nea.gov.kh

**ម.ក. ខេត្តកំពង់ចាម**

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ចាម ផ្លូវលេខ៧បាស់ ភូមិទី៧
សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
០៤២ ២១០ ២៧
ឬ ០១៦ ៦៥៦ ៦៥៥
jc_kampongcham@nea.gov.kh

**ម.ក. ខេត្តតាកែវ**

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោ
សែនតាកែវ ក្នុងភូមិ៣ សង្កាត់រការក្នុង
ក្រុងដូនកែវ ខេត្តតាកែវ
០៣២ ២១០ ២៧៧
ឬ ០១៦ ៦៧៦ ៦៥៥
jc_takeo@nea.gov.kh